បានថតចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម ។
កណ្តាល. ថ្ងៃទី០៩ ខែ 6 ឆ្នាំ ២០14
ក្រឡាបញ្ជី

[redacted]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងព្រហ្មទណ្ឌលេខ៖៨១៩ អក
ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០១២
សាលក្រមលេខ៖ 17 (ឆ.ព.ន)
ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៣

# តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្តាល

បានបើកសវនាការជំនុំជំម្រះជាសាធារណៈនៅសាលាដំបូងខេត្តកណ្តាលនាថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៣ វេលាម៉ោង ៩ និង០០នាទីព្រឹក ដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមជនុំជំម្រះសាលាដំបូងខេត្តកណ្តាល

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

ដើម្បីជំនុំជម្រះ លើសំណុំរឿងព្រហ្មទណ្ឌលេខ៖ ៨១៩ អក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ ដែលមាន ជនជាប់ចោទ៖

១-ឈ្មោះ: [redacted] ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើតនៅភូមិដីឥដ្ឋកោះផុស ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្ននៅភូមិចន្លក់ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល ឪពុកឈ្មោះ [redacted]ស) ម្តាយឈ្មោះ [redacted]ស់)។

២-ឈ្មោះ: [redacted]ហៅ ជ្រូក ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើតនៅភូមិចន្លក់ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្ននៅភូមិចន្លក់ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល ឪពុកឈ្មោះ: [redacted]រស់) ម្តាយឈ្មោះ: [redacted](រស់)។

1

Scanned by CamScanner

៣-ឈ្មោះ [redacted] ភេទប្រុស អាយុ ២៤ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើតនៅគីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ និងទីលំនៅបច្ចុប្បន្ននៅភូមិចន្លក់ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ឪពុកឈ្មោ[redacted]ស់) ម្ដាយឈ្មោ[redacted]រស់)។

៤-ឈ្មោះ [redacted]ហៅ បា ភេទប្រុស អាយុ ២០ឆ្នាំ ជាតិខ្មែរ មុខរបរៈ អ្នករត់តុការ មានទីកន្លែងកំណើតនៅភូមិចន្លក់ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល និងទីលំនៅបច្ចុប្បន្ននៅភូមិចន្លក់ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ឪពុកឈ្មោះ[redacted]ស) ម្ដាយឈ្មោះ[redacted]រ)។

៥-ឈ្មោះ [redacted]ភេទប្រុស អាយុ ២៤ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើតនៅភូមិកំពង់ក្របែក ឃុំតាសូស ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង និងទីលំនៅបច្ចុប្បន្ន នៅភូមិក្បាលជ្រោយ សង្កាត់វាលស្បូវ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោ[redacted]) ម្ដាយឈ្មោ[redacted])។

ត្រូវបានជាប់ចោទពីបទៈ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិចន្លក់ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

## ដំណើររឿងហេតុមានដូចតទៅ

នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១២ វេលាម៉ោង១៧.៣០នាទី មានឈ្មោ[redacted] ភេទប្រុស អាយុ២០ ឆ្នាំ ឈ្មោះ [redacted]ភេទប្រុស អាយុ២០,ឈ្មោះ [redacted] ភេទប្រុស អាយុ២៤ឆ្នាំ បានជិះម៉ូតូមួយគ្រឿងម៉ាកស្វាប ពណ៌ខ្មៅ សេរី ២០០៦ ពាក់ស្លាកលេខ ភ្នំពេញ ១K ៦៨៧០ សំដៅទៅភូមិចន្លក់ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល។ លុះជិះមកដល់ចំនុចផ្លូវលំក្រសាំង ស្ថិតក្នុងភូមិចន្លក់ ជនត្រូវចោទទាំងបីនាក់ បានឈប់ម៉ូតូបត់ជើងតូច ពេលនោះជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ ១៨ឆ្នាំ បានដើរពីផ្ទះនៅបត់ជើងធំក្នុងព្រៃ ក៏ជួបជាមួយឈ្មោះ [redacted] ហើយមានការជជែកគ្នា។ ភ្លាមនោះឈ្មោះ[redacted],ឈ្មោះ [redacted],ឈ្មោះ[redacted] បាននាំគ្នា ព្រួតវាយទៅលើឈ្មោះ[redacted] ហើយឈ្មោះ [redacted]បានយកដបទឹកត្រី មកវាយ ឈ្មោះ [redacted] មួយដបចំក្បាល ធ្វើឲ្យបែកដបត្រូវរបួស។ នៅពេលនោះឈ្មោះ [redacted]បានទៅឃាត់ ស្រាប់តែឈ្មោះ [redacted]ភេទប្រុស អាយុ ២៤ឆ្នាំ បានយកដំបងឈើជ្រុងវាយទៅលើឈ្មោះ[redacted] ដណ្ដើមដំបងពីឈ្មោះ [redacted]បាន ក៏វាយទៅលើឈ្មោះ[redacted]វិញ ត្រូវមួយដំបង និងបានវាយទៅលើឈ្មោះ[redacted]ទៀត។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ១៩០ ដកសព ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល។

បានឃើញ ដីកាដំណោះស្រាយលេខៈ ១៣០ ដកដស ចុះថ្ងៃទី២០ ខែ មីនា ឆ្នាំ២០១៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល។

បានឃើញ ចំណាត់ការចាត់តាំងចៅក្រមជំនុំជម្រះ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៣ ។



Scanned by CamScanner

# នាពេលសវនាការ

-ជនជាប់ចោទឈ្មោ[redacted]ានឆ្លើយថា៖ កាលពីថ្ងៃកើតហេតុមានមនុស្ស ៣នាក់ ឈ្មោះ[redacted] ឈ្មោះ[redacted]និងឈ្មោះ [redacted]បានបើកម៉ូតូមកជួបខ្លួនកំពុងដើរតាមផ្លូវ ស្រាប់តែអ្នកទាំង៣នោះ បានស្រែសួរខ្លួនថា ទៅណាដើរឡូយម្ល៉េះ ខ្លួនតបថាមិនឡូយទេ ដើរតែអញ់ទេ ពួកនេះក៏តបថា ចង់ត្រូវឬ? ហើយពួកនេះ ក៏ឈប់ម៉ូតូ ចុះមកវាយខ្លួននឹងដៃបណ្តាលឱ្យធ្លាក់អូរ ដោយឈ្មោះ [redacted] វាយខ្លួនត្រូវក្បាល និងមាត់, ឈ្មោះ [redacted]និងឈ្មោះ[redacted]ាយខ្លួនចំខ្លួនជាច្រើនដៃ ហើយខ្លួនក៏ងើបរត់ទៅផ្ទះ ទៅយកដប។ រួចក៏ត្រឡប់មកកន្លែងកើតហេតុវិញ ដើម្បីសួររកមូលហេតុ ខណៈពេលនោះ ក៏មានការប្រតាយប្រតប់គ្នាទៅវិញទៅមក ដោយអ្នកទាំង៣វាយខ្លួនដោយដៃទទេ រីឯខ្លួនក៏វាយតបវិញដោយដប ត្រូវក្បាលឈ្មោ[redacted]ណ្តាលឱ្យរងរបួសដួលទៅ មិនដឹងរបួសទំហំប៉ុណ្ណាទេ។ ចំណែកឈ្មោ[redacted]បានយកឈើជ្រុងវាយក្បាលខ្លួនឱ្យរបួស។ ឈ្មោះ[redacted]ធ្លាប់មានទំនាស់ជាមួយខ្លួនយូរហើយ។ បន្ទាប់មកឃើញឈ្មោះ[redacted]បានមកជួយឃាត់កុំឱ្យអ្នកទាំង៣ មកវាយខ្លួនស្រាប់តែឈ្មោះ [redacted]ាយឈ្មោះ[redacted]ណ្តាលឱ្យរបួសតែមិនធ្ងន់ធ្ងរទេ។ ខ្លួនស្នើសុំដល់តុលាការ មេត្តាជួយបន្ធូរបន្ថយទោសឱ្យខ្លួនផង។

-ជនជាប់ចោទឈ្មោះ[redacted]ានឆ្លើយថា៖ នៅថ្ងៃកើតហេតុម៉ោងប្រហែល៦ជាងថ្ងៃទី១៧ ខែ តុលា ឆ្នាំ២០១២ ខ្លួនកំពង់ដេកនៅផ្ទះម្តាយមីង ក្រឡេកទៅឃើញឈ្មោះ[redacted] ប្រវាយប្រតប់រុញគ្នាជាមួយមនុស្សប្រុសបីនាក់ មិនដឹងមានឈ្មោះអ្វីខ្លះទេ? ហើយខ្លួនឃើញឈ្មោ[redacted]ត់ទៅផ្ទះ ហើយត្រឡប់មកវិញដោយកាន់ដបពណ៌សថ្លាជាដបទឹកត្រី ដើរសំដៅទៅមនុស្សទាំងបីនាក់។ ពេលឃើញដូច្នេះខ្លួនក៏រើសបន្ទះក្តារពុម្ពផ្លាកកេប៉ុនពីរធ្នាប់ដៃប្រវែង៤ ទៅ៥តឹក នៅជិតនោះ បំណងទៅជួយឈ្មោះ[redacted] ព្រោះតែម្នាក់ឯង។ ពេលឈ្មោះ [redacted]ជួបអ្នកទាំងបី ឈ្មោះ [redacted]បានវាយប្រុសម្នាក់ត្រូវក្បាលបណ្តាលឲ្យបែកដប ឯខ្លួនស្ទុះទៅវាយឈ្មោះ [redacted] ត្រូវត្រូវចំក្បាលមួយបន្ទះឈើ ហើយរុញម្នាក់នោះចេញកុំឲ្យវាយឈ្មោះ[redacted] ត្រូវឈ្មោះ [redacted] ទាញដំបងពីរដៃវាយខ្លួនវិញ ត្រូវក្បាលបណ្តាលឲ្យបែកស្បែកក្បាល និងទាញឈើបណ្តាលឲ្យមុតបាតដៃ។ ខ្លួនស្នើសុំដល់តុលាការ មេត្តាជួយបន្ធូរបន្ថយទោសឱ្យខ្លួនផង។

-អំណានចម្លើយជនជាប់ចោទឈ្មោះ[redacted]ានឆ្លើយថា៖ នៅថ្ងៃកើតហេតុខ្លួនបើកបរម៉ូតូមួយគ្រឿងម៉ាកស្ទេប ពណ៌ខ្មៅ ផលិតនៅឆ្នាំ២០០៦ ជារបស់បងប្រុសខ្លួន ដោយដឹកមិត្តភ័ក្រ្តពីរនាក់ដែលមានឈ្មោះ [redacted]និងឈ្មោះ[redacted]ចេញពីភូមិស្លាបតាអោន ត្រឡប់មកផ្ទះ។ ពេលបើកម៉ូតូដល់ភូមិក្រសាំង ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល ក៏ឈប់ម៉ូតូបត់ជើងតូច ស្រាប់តែឈ្មោះ[redacted]កាន់ដបទឹកត្រីដើរមកដល់កន្លែង ខ្លួនឈប់ ក៏ស្រែកសួរថា ទៅណា ហើយក៏កើតទំនាស់ពាក្យសំដី ហើយមានការប្រកែកគ្នាទៅវិញទៅមក ស្រាប់តែឈ្មោះ[redacted]ស្ទុះទៅវាយឈ្មោះ [redacted]ត្រូវដៃឆ្វេង ឃើញដូចនេះ ខ្លួនក៏ស្ទុះទៅរុញឈ្មោះ[redacted]ចេញ ក៏មានមិត្តភក្រ្តវាម្នាក់ទៀតឈ្មោ[redacted]បានស្ទុះទាញដំបងវាយខ្លួនត្រូវក្បាលមួយដំបង និង ដៃស្តាំមួយដំបង បណ្តាលឲ្យដួលសន្លប់។ ពេលដឹងខ្លួនឡើងមិត្តភក្រ្តខ្លួន និងបក្សពួកឈ្មោះ[redacted]កំពុងប្រវាយប្រតប់គ្នា ខ្លួនស្ទុះទាញដំបងឈើប្រវែងប្រហែល ៦តឹក ពីដៃឈ្មោះ[redacted]វាយទៅលើឈ្មោ[redacted] មិនដឹងត្រូវ ឬខុសទេ រួចពួកខ្លួនឡើងជិះម៉ូតូមកផ្ទះតែម្តង។



Scanned by CamScanner

-អំណានចម្លើយជនជាប់ចោទឈ្មោះ[redacted]ានឆ្លើយថា ៖នៅថ្ងៃកើតហេតុ ឈ្មោះ[redacted] បានយកម៉ូតូម៉ាក់ស្មេបដឹកខ្លួននិងឈ្មោះ[redacted] ត្រឡប់មកផ្ទះវិញ។ ពេលមកដល់ពាក់កណ្តាលផ្លូវក៏បាន ឈប់បត់ជើងតូច ទន្ទឹមនោះមានឈ្មោះ [redacted] ដែលមានផ្ទះក្បែរនោះបានដើរមកតាមផ្លូវ ហើយឈ្មោះ [redacted] បានសួរនាំក៏កើតជាទំនាស់ពាក្យសំដីគ្នា។ ពេលនោះឈ្មោះ [redacted] បានរត់ទៅផ្ទះវាហើយ ត្រឡប់មកវិញ កាន់ដបទឹកត្រីមកជាមួយ ដោយរត់សំដៅមករកពួកខ្លួន រួចវាវាយខ្លួនត្រូវមួយដបបណ្តាលឲ្យពក ក្បាល និងបែកដប។ ខណៈនោះខ្លួនក៏បានវាយដោយដៃតបទៅវិញ ហើយឈ្មោះ[redacted]បានដាល់មកលើខ្លួន ត្រូវមុខមួយដៃ ខ្លួនក៏ដួល ហើយវាបានយកដបចាក់មកលើទ្រូងបណ្តាលឲ្យមុតចេញឈាម។ ពេលឃើញដូច នោះឈ្មោះ [redacted]ាបក្សពួករបស់ឈ្មោះ [redacted]ានរត់មកមានកាន់ឈើជ្រុងប្រវែងកន្លះម៉ែត្រមកវាយពួក ខ្លួន។ ពេលប្រវាយប្រតប់គ្នាឈ្មោះសារ៉ាត់ បានយកដំបងពីដៃឈ្មោះ [redacted] យកទៅវាយឈ្មោះ [redacted]តែ ឈ្មោ[redacted] រុញវាចេញ ហើយឈ្មោ[redacted] បានរត់ទៅហៅបក្សពួកមកជួយ ពេលនោះពួកខ្លួនបាននាំគ្នា ជិះម៉ូតូមកផ្ទះ។

-អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា៖ មុនកើតហេតុពួកខ្លួនបានឈប់ម៉ូតូ ត្រង់កន្លែងក្នុងភូមិសាស្រ្តា មិនស្គាល់ឈប់បត់ជើងតូច រូបខ្លួនកំពង់អង្គុយលើម៉ូតូ ឃើញភាគីម្ខាង មិនស្គាល់ ឈ្មោះ មានកាន់ដបសថ្លាគ្មានទឹក ដើរមកជួបមិត្តភក្រ្តខ្លួន ហើយវាយមិត្តភក្រ្ត ត្រូវក្បាលមួយដប បណ្តាលឲ្យ បែក ហើយវាយកដបនោះចាក់ត្រូវទ្រូង បណ្តាលឲ្យរងរបួស។ មិត្តភក្រ្តខ្លួនម្នាក់ទៀតបានទៅឃាត់ ស្រាប់តែ ពួកវាម្នាក់ទៀតកាន់ដំបងមកវាយមិត្តភក្រ្តខ្លួនមួយដំបង ហើយមិត្តភក្រ្តខ្លួនបានឆក់ដំបង នោះវាយតបវិញ ឯខ្លួនក៏ស្ទុះទៅឃាត់ចាប់ទាញដៃមិត្តភក្រ្តឡើងជិះម៉ូតូត្រឡប់មកផ្ទះវិញ។

-អំណានចម្លើយសាក្សីឈ្មោះ[redacted]បានឆ្លើយថាៈ កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១២ វេលាម៉ោង ១៧ និង៣០នាទី ខ្លួនកំពុងអង្គុយដាំបាយលើផ្ទះ ពេលដាំរួច ខ្លួនប្តូរសំលៀកបំពាក់ ចុះងូតទឹកក្រោមផ្ទះ បាន ឃើញក្មេងប្រុសចំនួន ៣នាក់ អាយុប្រហែល ២០ឆ្នាំ មិនស្គាល់ ឈរនៅមុខវិហារយាយស៊ូ មិនដឹងឈរធ្វើអ្វីទេ ពេលនោះឈ្មោ[redacted]ើរចេញមកពីកន្លែងបត់ជើង ស្រាប់តែក្មេងប្រុសទាំង ៣នាក់នោះ បានព្រួតគ្នាវាយ ឈ្មោះ[redacted]នឹងដៃ ឈ្មោះ [redacted]ានរត់ឱ្យខ្លួនជួយ ខ្លួនបានចាប់ឈ្មោះ[redacted]ក ហើយក្មេងប្រុស ទាំង ៣នាក់នោះ បានទះទ្រូង ប៉ោយដៃ ហៅចូល ដោយនិយាយថាៈ បង់ប្រាក់ ១,000,000 (មួយលាន) រៀល ស្រាប់តែឈ្មោ[redacted]ានរត់ទៅរកក្មេងប្រុសទាំង ៣នាក់នោះ ហើយឈ្មោ[redacted]ានរត់ទៅជាមួយ ដែរ ស្រាប់តែក្មេងប្រុសទាំង ៣នាក់ បានយកដបទឹកត្រី និងឈើបន្ទះក្តារប្រហែលកន្លះម៉ែត្រ វាយឈ្[redacted]ំ ក្បាលលើស្លឹកត្រចៀក ដួលមកលើដី ហើយឈ្មោះ[redacted]ចំក្បាលពីក្រោយ ដួលពីរបីត្រឡប់ ហើយក្មេង ប្រុសទាំង ៣នាក់នោះបានជិះម៉ូតូរត់បាត់។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ៖ ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ តំណាងអយ្យការ យល់ឃើញថា កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១២ ជនជាប់ចោទឈ្មោះ [redacted] ឈ្មោះ[redacted] ឈ្មោះ[redacted] ឈ្មោ[redacted] ឈ្មោ[redacted] ពិតជាបានវាយគ្នាទៅវិញទៅមកពិតប្រាកដមែន ដែលចម្លើយរបស់ជនជាប់ចោទពិតជាមានភាពស៊ីចង្វាក់ទៅនឹងឯកសារគតិយុត្តិនានារបស់មន្រ្តីនគរបាលយុត្តិ ធម៌។ ហេតុដូច្នេះតំណាងអយ្យការ សូមរក្សាការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពរលេខ៖ ១៩០ ដកសព



Scanned by CamScanner

ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៣ ទុកជាបានការទាំងស្រុង និងស្នើសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់

## សាលាដំបូងខេត្តកណ្តាល

## យល់ឃើញថា

១.ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយសារភាពថា៖ កាលពីថ្ងៃកើតហេតុខ្លួនបានយកដបវាយត្រូវក្បាលឈ្មោះ [redacted] បណ្តាលឱ្យរងរបួសដួលទៅ មិនដឹងរបួសទំហំប៉ុណ្ណាទេ។ ចំណែកឈ្មោះ [redacted] វាយខ្លួនត្រូវក្បាល និងមាត់, ឈ្មោះ [redacted] និងឈ្មោះ [redacted] វាយខ្លួនចំខ្លួនជាច្រើនដៃ។ បន្ទាប់មកឃើញឈ្មោះ [redacted] បានមកជួយឃាត់កុំឱ្យអ្នកទាំង៣ មកវាយខ្លួនស្រាប់តែឈ្មោះ [redacted] វាយឈ្មោះ [redacted] បណ្តាលឱ្យរបួស តែមិនធ្ងន់ធ្ងរទេ។

២.ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយសារភាពថា៖ នៅថ្ងៃកើតហេតុ ខ្លួនឃើញឈ្មោះ [redacted] រត់ទៅផ្ទះ ហើយត្រឡប់មកវិញដោយកាន់ដបពណ៌សថ្លាជាដបទឹកត្រី ដើរសំដៅទៅមនុស្សបីនាក់។ ខ្លួនក៏រើសបន្ទះក្តារពុម្ពផ្កាកកេប៉ុនពីរថ្នាប់ដៃប្រវែង៤ ទៅ៥តឹក នៅជិតនោះ បំណងទៅជួយឈ្មោះ [redacted] ព្រោះតែម្នាក់ឯង។ ពេលឈ្មោះ [redacted] ជួបអ្នកទាំងបី ឈ្មោះ [redacted] បានវាយប្រុសម្នាក់ត្រូវក្បាលបណ្តាលឲ្យបែកដប ឯខ្លួនស្ទុះទៅវាយឈ្មោះ [redacted] ត្រូវថ្ពៃមុខមួយបន្ទះឈើ ហើយរុញម្នាក់នោះចេញកុំឲ្យវាយឈ្មោះ [redacted] ត្រូវឈ្មោះ [redacted] ទាញដំបងពីរដៃ វាយខ្លួនវិញត្រូវក្បាលបណ្តាលឲ្យបែកស្បែកក្បាល និងទាញឈើបណ្តាលឲ្យមុតបាតដៃ។

៣.ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយសារភាពថា៖ នៅថ្ងៃកើតហេតុខ្លួនបើកបរម៉ូតូ ដឹកមិត្តភ័ក្ត្រពីរនាក់ដែលមានឈ្មោះ [redacted] និងឈ្មោះ [redacted] ចេញពីភូមិស្នួលតាអោន ត្រឡប់មកផ្ទះ។ ពេលបើកម៉ូតូដល់ភូមិក្រសាំង ឃុំគគីរ ស្រុកគៀនស្វាយ ខេត្តកណ្តាល ក៏ឈប់ម៉ូតូបត់ជើងតូច ស្រាប់តែឈ្មោះ [redacted] កាន់ដបទឹកត្រីដើរមកដល់កន្លែងខ្លួនឈប់ ក៏ស្រែកសួរថា ទៅណា ហើយក៏កើតទំនាស់ពាក្យសំដី ហើយមានការប្រកែកគ្នាទៅវិញទៅមក ស្រាប់តែឈ្មោះ [redacted] ស្ទុះទៅវាយឈ្មោះ [redacted] ត្រូវដៃឆ្វេង ឃើញដូចនេះ ខ្លួនក៏ស្ទុះទៅរុញឈ្មោះ [redacted] ចេញ ក៏មានមិត្តភក្ត្រវាម្នាក់ទៀតឈ្មោះ [redacted] បានស្ទុះទាញដំបងវាយខ្លួនត្រូវក្បាលមួយដំបង និងដៃស្តាំមួយដំបង បណ្តាលឲ្យដួលសន្លប់។ ខ្លួនស្ទុះទាញដំបងឈើប្រវែងប្រហែល ៦តឹក ពីដៃឈ្មោះ [redacted] វាយទៅលើឈ្មោះ [redacted] មិនដឹងត្រូវ ឬខុសទេ រួចពួកខ្លួនឡើងជិះម៉ូតូមកផ្ទះតែម្តង។



Scanned by CamScanner

៤.ជនជាប់ចោទឈ្មោ[redacted]បានឆ្លើយសាភាពថា៖ នៅថ្ងៃកើតហេតុឈ្មោ[redacted]បានកាន់ដបទឹកត្រី រត់សំដៅមករកពួកខ្លួន រួចវាយខ្លួនត្រូវមួយដបបណ្តាលឲ្យពកក្បាល និងបែកដប។ ខណៈនោះខ្លួនក៏បានវាយដោយដៃតបទៅវិញ ហើយឈ្មោះ[redacted]បានដាល់មកលើខ្លួនត្រូវមុខមួយដៃ ខ្លួនក៏ដួល ហើយវាបានយកដបចាក់មកលើទ្រូងបណ្តាលឲ្យមុតចេញឈាម។ ពេលឃើញដូចនោះឈ្មោះ[redacted]ជាបក្សពួករបស់ឈ្មោះ[redacted]នរត់មកមានកាន់ឈើជ្រុងប្រវែងកន្លះម៉ែត្រមកវាយពួកខ្លួន។

៥-ជនជាប់ចោទឈ្មោះ[redacted]នឆ្លើយថា៖ មុនកើតហេតុពួកខ្លួនបានឈប់ម៉ូតូត្រង់កន្លែងក្នុងភូមិសាស្ត្រា មិនស្គាល់ឈប់បត់ជើងតូច រួបខ្លួនកំពង់អង្គុយលើម៉ូតូ ឃើញភាគីម្ខាង មិនស្គាល់ឈ្មោះ មានកាន់ដបសប្លាគ្មានទឹក ដើរមកជួបមិត្តភក្រ័ខ្លួន ហើយវាយមិត្តភក្រ័ ត្រូវក្បាលមួយដប បណ្តាលឲ្យបែក ហើយវាយកដបនោះចាក់ត្រូវទ្រូង បណ្តាលឲ្យរងរបួស។ មិត្តភក្រ័ខ្លួនម្នាក់ទៀតបានទៅឃាត់ ស្រាប់តែពួកវាម្នាក់ទៀត កាន់ដំបងមកវាយមិត្តភក្រ័ខ្លួនមួយដំបង ហើយមិត្តភក្រ័ខ្លួនបានឆក់ដំបង នោះវាយតបវិញ ឯខ្លួនក៏ស្ទុះទៅឃាត់ចាប់ទាញដៃមិត្តភក្រ័ឡើងជិះម៉ូតូត្រឡប់មកផ្ទះវិញ។

៦.តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោ[redacted]ឈ្មោះ [redacted] ឈ្មោះ[redacted] ឈ្មោះ [redacted], ឈ្មោះ [redacted] និងសាក្សីឈ្មោះ[redacted]អាចបញ្ជាក់បានថា កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១២ ជនជាប់ចោទឈ្មោះ [redacted], ឈ្មោះ[redacted], ឈ្មោះ [redacted] ឈ្មោះ[redacted] និងឈ្មោះ [redacted] ពិតជាមានចេតនាប្រើហិង្សាលើគ្នាទៅវិញទៅមកបណ្តាលឱ្យមានរបួសទាំងសងខាងប្រាកដមែន ហើយអំពើប្រព្រឹត្តនេះ បង្កឡើងក្នុងនាមជាសហចារី ដោយការប្រើដប និងបន្ទះឈើធ្វើជាអាវុធ ដែលអំពើនេះច្បាប់ចាត់ទុកថាជា អំពើហិង្សា(ស្ថានទម្ងន់) ដែលតម្រូវឱ្យផ្តន្ទាទោសតាមបញ្ញាត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។ ហេតុដូច្នេះសាលាដំបូងគប្បីធ្វើការកែប្រែបទចោទពីបទ ហិង្សាដោយចេតនា ដែលតម្រូវឱ្យផ្តន្ទាទោសតាមបញ្ញាត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ មកបទ ហិង្សាដោយចេតនា (ស្ថានទម្ងន់) ដែលតម្រូវឱ្យផ្តន្ទាទោសតាមបញ្ញាត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌវិញ។

៧.អំពើរបស់ជនត្រូវចោទឈ្មោះ[redacted],ឈ្មោះ[redacted] ឈ្មោះ[redacted], ឈ្មោះ [redacted] ឈ្មោះ[redacted]បានធ្វើឲ្យប៉ះពាល់ដល់រូបកាយបុគ្គលឯកជន, សន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសង្គមសាធារណៈ ហើយជនត្រូវចោទជានីតិជនមានស្មារតីយល់ដឹងគ្រប់គ្រាន់ចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត និងក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន។

៨.មានភស្តុតាង និងធាតុផ្សំគ្រប់គ្រាន់លើឈ្មោះ[redacted]ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ,ឈ្មោះ[redacted]ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ ,ឈ្មោះ[redacted]ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ, ឈ្មោ[redacted] ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted]ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ ពីបទ៖ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិចន្លក់ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។

៩.វត្ថុតាងមានៈ កំទេចអំបែងដបចំនួន ១ខាំ ដូចមាននៅក្នុងកំណត់ហេតុទទួលវត្ថុតាងចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ របស់តំណាងអយ្យការ គឺជាសម្ភារៈប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស គប្បីតុលាការសម្រេចរឹបអូសបំផ្លាញចោល តាមមាត្រា៦២ នៃក្រមព្រហ្មទណ្ឌ។



Scanned by CamScanner

<u>ហេតុដូច្នេះសម្រេចសេចក្តី</u>

១-កែប្រែបទចោទលើឈ្មោះ [redacted] ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ,ឈ្មោះ [redacted] ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] ភេទប្រុស អាយុ ២៤ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ ពីបទៈ ហិង្សាដោយចេតនា បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ មកបទៈ ហិង្សាដោយចេតនា (មានស្ថានទម្ងន់) ប្រព្រឹត្តនៅភូមិចន្លក់ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។

២-ផ្តន្ទាទោសឈ្មោះ [redacted] ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] ប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន ០២ (ពីរ)ឆ្នាំ ពីបទៈ ហិង្សាដោយចេតនា (មានស្ថានទម្ងន់) ប្រព្រឹត្តនៅភូមិចន្លក់ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។

៣-រឹបអូសវត្ថុតាងមានៈ កំទេចអំបែងដបចំនួន ១ខាំ បំផ្លាញចោល។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនាថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៣ និងប្រកាសជាសាធារណៈនាថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ឈ្មោះ [redacted] និងឈ្មោះ [redacted]

ទុកសិទ្ធប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ក្រឡាបញ្ជីសវនាការ

[redacted]

ចៅក្រមជំនុំជម្រះ

[redacted]



Scanned by CamScanner